**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**
លេខ: ៨៨៩/១៦ ប.ស.ស

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦*

**បេឡាជាតិរបបសន្តិសុខសង្គម**
**ជម្រាបមក**

**លោក/លោកស្រីនាយកសហគ្រាស យឺន ដុន ស៊ូ ខូ អិលធីឌី**

**លេខអត្តសញ្ញាណសហគ្រាស** | ១ | ០ | ០ | ១ | ២ | ៩ | ៨ | ៥ |

**<u>កម្មវត្ថុ</u>** ៖ អំពីកាតព្វកិច្ចរបស់និយោជក និងកម្មករនិយោជិត ក្នុងការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ។

**<u>យោង</u>** ៖

- អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ប្រកាសលេខ ០៩៣/១៦ ក.ប/ប្រ.ក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការកំណត់ដំណាក់កាល និងកាលបរិច្ឆេទ នៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
- ប្រកាសលេខ ២២០/១៦ ក.ប/ប្រ.ក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការកំណត់អត្រាភាគទាន និងបែបបទនៃការបង់ភាគទាន សម្រាប់ផ្នែកថែទាំសុខភាព ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ បេឡាជាតិរបបសន្តិសុខសង្គម សូមជូនដំណឹងដល់លោក/លោកស្រីជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត ឲ្យបានជ្រាបថា សហគ្រាស គ្រឹះស្ថាន របស់លោក/លោកស្រី ត្រូវមានកាតព្វកិច្ចអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ ។ ការបង់ភាគទានគិតចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៦ ហើយកម្មករនិយោជិតនឹងទទួលបានសិទ្ធិប្រើប្រាស់សេវាសុខាភិបាល ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

ក្នុងករណីដែលលោក/លោកស្រីនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត មិនព្រមអនុវត្តតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើនេះទេ បេឡាជាតិរបបសន្តិសុខសង្គម នឹងចាត់វិធានការតាមច្បាប់ជាធរមាន ។

បេឡាជាតិរបបសន្តិសុខសង្គម សង្ឃឹមយ៉ាងមុតមាំថា លោក/លោកស្រីជានិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន នឹងចូលរួមអនុវត្តតាមខ្លឹមសារនេះជាក់ជាពុំខាន ៕

**នាយក**

**អ៊ុក សមវិទ្យា**

**អ្នកទទួលលិខិត**

ឈ្មោះ ៖....................................
តួនាទី ៖....................................
លេខទូរស័ព្ទ ៖............................



Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប.ស.ស NSSF National Social Security Fund

**បេឡាជាតិរបបសន្តិសុខសង្គម**
លេខ: ៥៨៥/១៦ ប.ស.ស

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦

## បេឡាជាតិរបបសន្តិសុខសង្គម
## ជម្រាបមក

**លោក/លោកស្រីនាយកសហគ្រាស** YING DONG SHOES CO., LTD.

**លេខអត្តសញ្ញាណសហគ្រាស** ១០០០១៦៩៨៥៥

**កម្មវត្ថុ ៖** ការចុះកំណត់អត្តសញ្ញាណកម្មករ និយោជិត សម្រាប់ការចុះបញ្ជិកានៅបេឡាជាតិរបបសន្តិសុខសង្គម ។

**យោង ៖** សេចក្តីជូនដំណឹងលេខ ១២៧ ក.ប/ស.ជ.ណ ស្តីពីការចុះបញ្ជិកាកម្មករ និយោជិត ក្នុងបេឡាជាតិរបបសន្តិសុខសង្គម ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ បេឡាជាតិរបបសន្តិសុខសង្គម មានកិត្តិយសសូមជម្រាបជូន លោក/លោកស្រី ជ្រាបថា ប.ស.ស បានចាប់ផ្តើមចុះកំណត់អត្តសញ្ញាណកម្មករ និយោជិត ដែលបានចុះបញ្ជិកានៅក្នុង ប.ស.ស ឡើងវិញទាំងអស់ ក្នុងគោលបំណងងាយស្រួលក្នុងការបើកផ្តល់តាវកាលិកជូនដល់សមាជិក និងត្រៀមអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកសោធននិវត្តន៍ ។

ដូចនេះ ប.ស.ស នឹងចាប់ផ្តើមចុះកំណត់អត្តសញ្ញាណកម្មករ និយោជិត នៅក្នុងសហគ្រាសរបស់លោក/លោកស្រី ចាប់ពីថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ តទៅ ។

អាស្រ័យដូចជម្រាបជូនខាងលើ សូមលោក/លោកស្រី មេត្តាពិនិត្យ និងជួយសហការ ដើម្បីឲ្យការងារនេះទទួលបានជោគជ័យ ។

សូមលោក/លោកស្រី មេត្តាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**នាយក**

**អ៊ុក សមវិទ្យា**

**អ្នកទទួលលិខិត**

ឈ្មោះ ៖........................................

តួនាទី ៖........................................

លេខទូរស័ព្ទ ៖...............................



Scanned with CamScanner